***If you are Parks Tacoma Staff submitting on behalf of an applicant:***

***Staff Member (please print):***

***Location:***

ឆ្នាំប្រតិទិនដែលដាក់ពាក្យស្នើសុំ៖ 2025

# ការដាក់ពាក្យសុំជំនួយហិរញ្ញវត្ថុ

Parks Tacoma ផ្តល់ជូនកម្មវិធីជំនួយហិរញ្ញវត្ថុដែលបុគ្គលទាំងឡាយ និងក្រុមគ្រួសារនានាអាចស្នើសុំជំនួយហិរញ្ញវត្ថុបាន នៅរៀងរាល់ឆ្នាំប្រតិទិនសម្រាប់ថ្នាក់សិក្សានិងកម្មវិធីកម្សាន្តដោយមានបង់ប្រាក់តាមកាលវិភាគកំណត់ និងសមាជិកភាពមជ្ឈមណ្ឌលសហគមន៍។

---

## <u>សិទ្ធិទទួលបាន</u>

ក្រុមគ្រួសារត្រូវតែជាអ្នករស់នៅក្នុងដែនកំណត់នៃទីក្រុង Tacoma ស្របទៅតាមគេហទំព័រទីក្រុង Tacoma ខាងក្រោម (គ្រប់សមាជិកគ្រួសារទាំងអស់ នឹងទទួលបានជំនួយហិរញ្ញវត្ថុ) ឬមានកូនដែលចូលរៀនក្នុងសាលាសាធារណៈទីក្រុង Tacoma (មានតែកុមារដែលចូលរៀននៅក្នុង TPS ប៉ុណ្ណោះនឹងទទួលបានជំនួយហិរិញ្ញវត្ថុ) និងបំពេញតាមកម្រិតប្រាក់ចំណូលដែលមានលក្ខណសម្បត្តិគ្រាប់គ្រាន់ ផ្អែកតាមកម្រិតប្រាក់ចំណូលដែលកំណត់ដោយក្រសួងអភិវឌ្ឍលំនៅដ្ឋាននិងទីក្រុងសហរដ្ឋអាមេរិក (HUD) សម្រាប់តំបន់ទីប្រជុំជន Tacoma។

## <u>គោលការណ៍ណែនាំ</u>

- ក្រុមគ្រួសាររួមមាន៖ គ្រួសារជិតស្និទ្ធបំផុត (កូនៗ ឪពុកម្ដាយ ប្តីប្រពន្ធ អាណាព្យាបាល ឬ ជីដូនជីតា) ដែលរស់នៅ នៅក្នុងក្រុមគ្រួសារតែមួយ ។ មនុស្សពេញវ័យគឺជាបុគ្គលដែលមានអាយុ 19 ឆ្នាំ ឬច្រើនជាងនេះ ហើយក្រុមគ្រួសារមួយមិនអាចមានមនុស្សពេញវ័យលើសពី 3 នាក់បានទេ។ មនុស្សពេញវ័យបន្ថែមទៀតដែលរស់នៅក្នុងក្រុមគ្រួសារតែមួយ អាចដាក់ពាក្យសុំដាច់ដោយឡែកបាន។
- ក្រុមគ្រួសារត្រូវតែដាក់ពាក្យសុំសាឡើងវិញនៅរៀងរាល់ឆ្នាំប្រតិទិននីមួយៗ ដើម្បីផ្ទៀងផ្ទាត់សិទ្ធិទទួលបានជាបន្ត។
- ជំនួយហិរញ្ញវត្ថុ ត្រូវតែបានដាក់ពាក្យសុំនៅមុនពេលចុះឈ្មោះសម្រាប់សកម្មភាពមួយ ឬចុះឈ្មោះចូលជាសមាជិក មិនអាចដាក់ពាក្យសុំជំនួយជាក្រោយឡើយ។
- ការទទួលបានជំនួយហិរញ្ញវត្ថុ មិនចុះឈ្មោះអ្នកដោយស្វ័យប្រវត្តិទៅក្នុងកម្មវិធីមួយ ឬចុះឈ្មោះអ្នកជាសមាជិកនោះទេ។ នៅពេលដែលជំនួយហិរញ្ញវត្ថុត្រូវបានអនុវត្តវត្តទៅលើគណនីរបស់អ្នក អ្នកចាំបាច់ត្រូវចុះឈ្មោះ និងបង់ទឹកប្រាក់សហបង់ប្រាក់។

---

## <u>ដំណើរការដាក់ពាក្យសុំ</u>

1. បំពេញព័ត៌មាននៅលើពាក្យសុំទាំងសងខាង ចុះហត្ថលេខាខាងក្រោម និងកាលបរិច្ឆេទ។
2. ប្រគល់ទម្រង់បែបបទទៅកាន់ Parks Tacoma។
   - ✓ អ៊ីមែលទម្រង់បែបបទទៅកាន់ mptfinancialassistance@tacomaparks.com
   - ✓ ដាក់ឯកសារនៅការិយាល័យកណ្តាលរបស់ Parks Tacoma នៅអាសយដ្ឋាន 4702 S. 19th St, Tacoma, WA 98405
   - ✓ ដាក់ឯកសារនៅមជ្ឈមណ្ឌលសហគមន៍មួយក្នុងចំណោមមជ្ឈមណ្ឌលសហគមន៍ទាំងបួនរបស់ (Center at Norpoint, Eastside Community Center, People's Community Center, STAR Center) ដែលអាចផ្ញើទម្រង់តាមអ៊ីមែលទៅកាន់ mptfinancialassistance@tacomaparks.com
   - ✓ ផ្ញើទម្រង់តាមសំបុត្រទៅកាន់៖ Parks Tacoma / Attn: Financial Assistance / 4702 S 19th St, Tacoma, WA 98405
3. នៅពេលដែលពាក្យសុំទាំងមូលត្រូវបានប្រគល់ សូមទុកពេល 3 ថ្ងៃធ្វើការសម្រាប់ដំណើរការឯកសារ។ អ្នកនឹងទទួលបានការជូនដំណឹងតាមអ៊ីមែល នៅពេលជំនួយហិរញ្ញវត្ថុរបស់អ្នកត្រូវបានអនុវត្តទៅលើគណនីរបស់អ្នក។
4. សម្រាប់ជំនួយលើពាក្យសុំឬសំណួរ សូមទូរសព្ទទៅលេខ (253) 305-1030។

---

**តាមរយៈការចុះហត្ថលេខាខាងក្រោម ខ្ញុំសូមបញ្ជាក់ថា រាល់ព័ត៌មានទាំងអស់ នៅក្នុងពាក្យសុំនេះគឺត្រឹមត្រូវពិតប្រាកដ។ ខ្ញុំសូមបញ្ជាក់ថា អាសយដ្ឋានរបស់ខ្ញុំគឺស្ថិតនៅក្នុងដែនកំណត់នៃទីក្រុង Tacoma (បានផ្ទៀងផ្ទាត់ទៅលើគេហទំព័រនៃទីក្រុង Tacoma) ឬកូនរបស់ខ្ញុំរៀននៅសាលាសាធារណៈទីក្រុង Tacoma។ ខ្ញុំសូមបញ្ជាក់ថា ក្រុមគ្រួសាររបស់ខ្ញុំបំពេញតាមគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានប្រាក់ចំណូលដែលមានរៀបរាប់នៅក្នុងពាក្យសុំនេះសម្រាប់ទំហំគ្រួសាររបស់ខ្ញុំ។ ខ្ញុំយល់ថា ព័ត៌មាននេះផ្តល់ជូនសម្រាប់គោលបំណងទទួលបានសេវាដោយឥតគិតថ្លៃ ឬដែលមានបញ្ចុះតម្លៃ និងយល់ច្បាស់ថា Parks Tacoma អាចផ្ទៀងផ្ទាត់ព័ត៌មាននៅលើពាក្យសុំនេះបាន។ ការផ្តល់ជូនព័ត៌មានមិនត្រឹមត្រូវដោយចេតនា អាចនឹងបណ្តាលឱ្យខ្ញុំត្រូវទទួលទោសក្រោមច្បាប់រដ្ឋនិងសហព័ន្ធជាធរមាន។ ខ្ញុំបានអាន និងយល់ច្បាស់គ្រប់លក្ខខណ្ឌទាំងអស់ដែលពាក់ព័ន្ធនឹងកម្មវិធីជំនួយហិរញ្ញវត្ថុនេះ។ ខ្ញុំយល់ច្បាស់ថា ពាក្យសុំនេះផុតសុពលភាពនៅថ្ងៃទី 31 ខែធ្នូ ហើយតម្រូវឱ្យមានការបន្តសុពលភាពសម្រាប់ឆ្នាំបន្ទាប់។**

---

**ហត្ថលេខាសមាជិកគ្រួសារជាមនុស្សពេញវ័យ** **កាលបរិច្ឆេទ**

1. **ជ្រើសរើសរបៀបដែលអ្នកកំពុងដាក់ពាក្យសុំ៖**

☐ **ពួកយើងរស់នៅក្នុងដែនកំណត់នៃទីក្រុង Tacoma ដូច្នេះសមាជិកគ្រួសារទាំងអស់របស់ខ្ញុំ នឹងទទួលបានជំនួយហិរញ្ញវត្ថុ។** ខ្ញុំបានបញ្ចូលអាសយដ្ឋានផ្ទះរបស់ខ្ញុំទៅក្នុងគេហទំព័រនេះ ហើយអាសយដ្ឋានគឺស្ថិតនៅក្នុងមណ្ឌលមួយក្នុងចំណោមមណ្ឌលក្រុមប្រឹក្សាទីក្រុង Tacoma។ https://www.cityoftacoma.org/government/city_council/district_map

☐ **ពួកយើងមិនរស់នៅក្នុងដែនកំណត់ទីក្រុង Tacoma ទេ ប៉ុន្តែកូនរបស់ពួកយើងចូលរៀននៅក្នុងសាលាសាធារណៈទីក្រុង Tacoma ដូច្នេះមានតែក្មេងៗដែលចូលរៀននៅសាលា TPS ប៉ុណ្ណោះទើបទទួលបានជំនួយហិរញ្ញវត្ថុ។**

| *ឈ្មោះកុមារ* | *ឈ្មោះសាលាសាធារណៈ Tacoma* |
|---|---|
| | |
| | |
| | |
| | |

2. **ជ្រើសរើសកម្រិតប្រាក់ជំនួយ (75% ឬ 50%) ដែលអ្នកមានលក្ខណសម្បត្តិទទួលបាន៖**

☐ **យើងមានលក្ខណសម្បត្តិទទួលបានកម្រិតប្រាក់ជំនួយ 75% ដោយសារយើងរកបានតិចជាងឬស្មើនឹងចំណូលប្រចាំឆ្នាំ/ខែ សម្រាប់ទំហំគ្រួសាររបស់ខ្ញុំ/របស់យើង។**

☐ **យើងមានលក្ខណសម្បត្តិទទួលបានកម្រិតប្រាក់ជំនួយ 50% ដោយសារយើងរកបានតិចជាងឬស្មើនឹងចំណូលប្រចាំឆ្នាំ/ខែ សម្រាប់ទំហំគ្រួសាររបស់ខ្ញុំ/របស់យើង។**

*កម្រិតប្រាក់ចំណូលដែលកំណត់ដោយ HUD សម្រាប់តំបន់ទីប្រជុំជន Tacoma*

| ប្រភេទកម្រិតប្រាក់ចំណូលសម្រាប់ឆ្នាំសារពើពន្ធ 2024 | ចំនួនសមាជិកក្នុងគ្រួសារ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| កម្រិតប្រាក់ចំណូលប្រចាំឆ្នាំដែលមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុ 50% | $40,550.00 | $46,350.00 | $52,150.00 | $57,900.00 | $62,550.00 | $67,200.00 | $71,800.00 | $76,405.000 |
| កម្រិតប្រាក់ចំណូលប្រចាំឆ្នាំដែលមានសិទ្ធិទទួលបាន ជំនួយហិរញ្ញវត្ថុ 75% | $24,350.00 | $27,800.00 | $31,300.00 | $34,750.00 | $37,550.00 | $41,960.00 | $47,340.00 | $52,750.00 |

## បញ្ជីរាយនាមមេគ្រួសារ

នាមខ្លួននិងនាមត្រកូល ______________________ ថ្ងៃខែឆ្នាំកំណើត ______________

អាសយដ្ឋានផ្លូវ ទីក្រុង ហ្ស៊ីបកូដ ______________________________

អ៊ីមែល ______________________ លេខទូរសព្ទ ______________

នាមខ្លួននិងនាមត្រកូលបុគ្គលទំនាក់ទំនងពេលមានអាសន្ន______________ត្រូវជា______________

លេខទូរសព្ទទាក់ទង______________

ជ្រើសរើសភេទ៖ ☐ ប្រុស ☐ ស្រី ☐ អ្នកដែលមិន ☐ អ្នកដែលមិនកំណត់យេនឌ័រខ្លួនឯង ☐ អ្នកប្តូរយេនឌ័រ ☐ ផ្សេងៗ

## រៀបរាប់សមាជិកផ្សេងទៀតនៅក្នុងគ្រួសារដែលមានលក្ខណសម្បត្តិទទួលបានជំនួយហិរញ្ញវត្ថុ

| នាមខ្លួន | នាមត្រកូល | ថ្ងៃខែឆ្នាំកំណើត | ភេទ |
|---|---|---|---|
| | | | ☐ ប្រុស ☐ ស្រី ☐ អ្នកដែលមិនមានអត្តសញ្ញាណភេទ ☐អ្នកដែលមិនកំណត់យេនឌ័រខ្លួនឯង ☐ អ្នកប្តូរយេនឌ័រ ☐ ផ្សេងៗ |
| | | | ☐ ប្រុស ☐ ស្រី ☐ អ្នកដែលមិនមានអត្តសញ្ញាណភេទ ☐អ្នកដែលមិនកំណត់យេនឌ័រខ្លួនឯង ☐ អ្នកប្តូរយេនឌ័រ ☐ ផ្សេងៗ |
| | | | ☐ ប្រុស ☐ ស្រី ☐ អ្នកដែលមិនមានអត្តសញ្ញាណភេទ ☐អ្នកដែលមិនកំណត់យេនឌ័រខ្លួនឯង ☐ អ្នកប្តូរយេនឌ័រ ☐ ផ្សេងៗ |
| | | | ☐ ប្រុស ☐ ស្រី ☐ អ្នកដែលមិនមានអត្តសញ្ញាណភេទ ☐អ្នកដែលមិនកំណត់យេនឌ័រខ្លួនឯង ☐ អ្នកប្តូរយេនឌ័រ ☐ ផ្សេងៗ |
| | | | ☐ ប្រុស ☐ ស្រី ☐ អ្នកដែលមិនមានអត្តសញ្ញាណភេទ ☐អ្នកដែលមិនកំណត់យេនឌ័រខ្លួនឯង ☐ អ្នកប្តូរយេនឌ័រ ☐ ផ្សេងៗ |
| | | | ☐ ប្រុស ☐ ស្រី ☐ អ្នកដែលមិនមានអត្តសញ្ញាណភេទ ☐អ្នកដែលមិនកំណត់យេនឌ័រខ្លួនឯង ☐ អ្នកប្តូរយេនឌ័រ ☐ ផ្សេងៗ |
| | | | ☐ ប្រុស ☐ ស្រី ☐ អ្នកដែលមិនមានអត្តសញ្ញាណភេទ ☐អ្នកដែលមិនកំណត់យេនឌ័រខ្លួនឯង ☐ អ្នកប្តូរយេនឌ័រ ☐ ផ្សេងៗ |